# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥០...សសរ..

## សេចក្តីសម្រេច
## ស្តីពី
## ការរៀបចំកិច្ចប្រជុំនៃក្រុមពិគ្រោះយោបល់លើកទី៨

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/០០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៧០ អនក្រ.បក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអនុក្រឹត្យរបស់រាជរដ្ឋាភិបាល លេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០០៤ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧០ អនក្រ.បក
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

### សម្រេច

**ប្រការ ១ :** ប្រគល់ភារកិច្ចជូនឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាអនុប្រធានទី១នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្នុងការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំ សំរាប់កិច្ចប្រជុំពិគ្រោះយោបល់លើកទី ៨ ដែលនឹងប្រព្រឹត្តទៅ នាខែមិនា ឆ្នាំ ២០០៦ ខាងមុខនេះ ។

**ប្រការ ២ :** ក្នុងក្របខ័ណ្ឌនៃការដឹកនាំនិងសំរបសំរួលការងារត្រៀមរៀបចំសំរាប់កិច្ចប្រជុំនេះ ឯកឧត្តម **គាត ឈន់** ត្រូវសហការជាមួយប្រធាននៃបណ្តាក្រសួងនិងស្ថាប័នទាំងអស់នៃរាជរដ្ឋាភិបាល និងមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់

អោយចូលរួមប្រជុំអន្តរក្រសួង និងមានសិទ្ធិចាត់តែងពិគ្រោះយោបល់ជាមួយបណ្តាដៃគូអភិវឌ្ឍន៍ទាំងអស់ ដើម្បីសំរបសំរួលការងារ និងដើម្បីរៀបរំសេចក្តីព្រាងឯកសារចាំបាច់ៗនានា ។

**ប្រការ ៣** : ឯកឧត្តម **គាត ឈន់** ត្រូវរាយការណ៍ជាបន្តបន្ទាប់ជូនសម្តេចនាយករដ្ឋមន្ត្រី អំពីវឌ្ឍនភាពនៃការរៀបចំ ហើយត្រូវរៀបចំឯកសារចាំបាច់នានាសំរាប់កិច្ចប្រជុំលើកទី ៨ នេះ ដើម្បីដាក់ជូនសម្តេចនាយករដ្ឋមន្ត្រីពិនិត្យ ផ្តល់យោបល់ណែនាំ និងអនុម័ត មុននឹងយកទៅប្រើប្រាស់ជាផ្លូវការ ។

**ប្រការ ៤** : ក្នុងការបំពេញកិច្ចការនេះ ឯកឧត្តម **គាត ឈន់** ប្រើប្រាស់ខេនាសម្ព័ន្ធរបស់គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (កអក/គជនា) ដែលមានឯកឧត្តម **ឈៀង យ៉ាណារ៉ា** ជាអគ្គលេខាធិការ សំរាប់ជំនួយការងារប្រចាំថ្ងៃ ។

**ប្រការ ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួងនិងស្ថាប័នពាក់ព័ន្ធ និងឯកឧត្តម **គាត ឈន់** ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ ៦** : សេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខារហូតដល់កិច្ចប្រជុំលើកទី៨ នៃក្រុមពិគ្រោះយោបល់បានប្រព្រឹត្តទៅចប់សព្វគ្រប់ ។

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែ វិច្ឆិកា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ដូចប្រការ៥ " ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ